

# កូស៊ី អ្នកស៊ើបអង្កេតចិត្តល្អ


N. Chokkan

Megha Vishwanath



letsreadasia.org



នៅព្រឹកមួយ កុមារឈ្មោះកូស៊ី ស្រមៃ
ថាខ្លួនឯងជាអ្នកស៊ើបអង្កេត។ ប៉ុន្តែ
អ្នកស៊ើបអង្កេតនេះមានតែពិលថ្មីមួយ
និងកែវពង្រីកមួយប៉ុណ្ណោះដែលទិញពី
ហាងក្នុងភូមិ។



តារបស់កូស៊ី បានប្រាប់ថា ”កូស៊ី ថ្ងៃនេះ ចៅមើលទៅដូចអ្នកស៊ើបអង្កេតមែនទែន។ តា ចង់ដឹងថា ចៅនឹងស៊ើបអង្កេតរកអ្វី”។ កូស៊ី រំភើបយ៉ាងខ្លាំង ហើយដើរយ៉ាងលឿនចូលក្នុងព្រៃនៅជិតចម្ការ។



កូស៊ី សម្លឹងមើលស្មៅសើម និងប្រាប់ខ្លួនឯងថា "ហឺ! ខ្ញុំគិតថា កន្លែងនេះទើបតែភ្លៀងរួច"។



ពិល និងកែវពង្រីក ពិតជាជួយបាន
ច្រើន។ កូស៊ី បានរកឃើញតម្រុយ
ដំបូងហើយ។ ប៉ុណ្ណឹង ល្អហើយ
សម្រាប់អ្នកស៊ើបអង្កេតថ្មីថ្មោង។
បន្ទាប់មក កូស៊ី អង្កេតឃើញថានៅលើ
ស្មៅ មានអ្វីមួយចំនួនពណ៌ក្រហម។
តើនោះអាចជាអ្វីទៅ?



នោះមើលទៅដូចជាផ្សិត។ ប៉ុន្តែ តើអ្នកស៊ើបអង្កេត គួរទទួលយកថានោះជាផ្សិតមែនឬអត់? កូស៊ី ចង់ឱ្យច្បាស់ពិតប្រាកដ ដូច្នេះក៏ដើរចុងជើងថ្នមៗទៅជិតកន្លែងពណ៌ក្រហមនោះ យកកែវពង្រីកចេញ ហើយឆ្លុះមើល។ គួរឱ្យភ្ញាក់ផ្អើលមែនទែន! កូស៊ី ឃើញកុមារីតូចម្នាក់កំពុងអង្គុយកាន់ឆត្រពណ៌ក្រហមនៅទីនោះ។



កូស៊ី សម្លឹងមើលកុមារីនោះតាមកែវពង្រីក។ កូស៊ី សួរដោយសំឡេងខ្លាំងៗថា "តើឯងជានរណា? ធ្វើអីនៅទីនេះ?" កុមារីតូច ភ័យខ្លាចដោយសារសំឡេងខ្លាំងៗនេះ និងគ្រាប់ភ្នែករីកធំរបស់កូស៊ី នៅក្នុងកែវពង្រីក។ កុមារីតូចក៏បោះចោលឆត្រ ហើយថយក្រោយទាំងភ័យខ្លាច។



តាមកែវពង្រីក កូស៊ី អាចមើលឃើញ
ទឹកមុខរបស់កុមារីតូចយ៉ាងច្បាស់។
កុមារីតូច មើលទៅភ័យខ្លាច។ ដូច្នេះ
កូស៊ី ប្រាប់កុមារីតូច ដោយសុភាពថា
"កុំភ័យៗ។ ខ្ញុំមិនធ្វើបាបឯងទេ។ ខ្ញុំចង់
ធ្វើជាមិត្តឯងទេ"។



កុមារីតូច សម្លឹងមើលកូស៊ីមួយសន្ទុះ ហើយសួរតិចៗថា ”នៅភ្លៀងមែនទេ?” កូស៊ីឆ្លើយថា ”អត់ទេ ឈប់ភ្លៀងយូរហើយ។ ឥឡូវ មិនចាំបាច់ប្រើឆត្រទៀតទេ។ ឯងអាចប្រាប់មិត្តឯងអ៊ីចឹងដែរទៅ”។



កុមារីតូច ក៏ឡើងជាន់លើមួករបស់កូស៊ី ហើយញញឹមដាក់កូស៊ី។ កុមារីតូចប្រាប់ថា ”ខ្ញុំឈ្មោះឡាលីថា។ ខ្ញុំរស់នៅក្នុងព្រៃនេះជាមួយគ្រួសារខ្ញុំ។ យើងអត់ចេះធ្វើផ្ទះទេ។ ដូច្នេះ នៅពេលមេឃភ្លៀង យើងប្រើឆត្រកុំឱ្យទទឹក”។



កូស៊ី ប្រាប់វិញថា ”ខ្ញុំអាចបង្រៀនឯង
និងគ្រួសារឯងឱ្យចេះធ្វើផ្ទះ។ ឪពុកខ្ញុំ
និយាយថា ខ្ញុំអាចក្លាយជាស្ថាបត្យករ
ដ៏អស្ចារ្យនៅថ្ងៃណាមួយ”។ ក្តីសុបិន្ត
របស់កូស៊ី ដែលចង់ក្លាយជាអ្នកស៊ើប
អង្កេត ក៏ចប់នៅត្រឹមនេះ ហើយ
ចាប់ផ្តើមមានក្តីសុបិន្តថ្មីមួយទៀត៕

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
Kaushik, the Kind Detective, author: N. Chokkan. illustrator: by Megha Vishwanath. Published by Pratham Books, https://storyweaver.org.in/stories/2171-kaushik-the-kind-detective © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Somey Chheang